មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

កាលពីឆ្នាំ២០១៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត និងប្រកាសយកថ្ងៃទី២ ខែវិច្ឆិកា ជា«ទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន»។ សេចក្តីសម្រេចនេះថ្កោលទោសគ្រប់ទម្រង់នៃការវាយប្រហារនិងការប្រើអំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងជំរុញរដ្ឋភាគីឱ្យអនុវត្តនូវវិធានការជាក់លាក់ប្រយុទ្ធប្រឆាំងលើវប្បធម៌និទណ្ឌភាព។ ជាមួយគ្នានេះ អង្គការសហប្រជាជាតិតម្រូវឱ្យរដ្ឋជាភាគីទប់ស្កាត់នូវរាល់អំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធានានូវគណនេយ្យភាព នាំខ្លួនជនល្មើសលើអ្នកសារព័ត៌មាន និងអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយមកកាត់ទោស និងធានាថាជនរងគ្រោះទទួលបាននូវដំណោះស្រាយ។ បន្ថែមលើនេះ ទិវានេះក៏អំពាវនាវដល់រដ្ឋជាភាគីក្នុងការលើកកម្ពស់ និងបង្កបរិយាកាសដែលមានសុវត្ថិភាពដល់អ្នកសារព័ត៌មានអាចបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងមិនមានការជ្រៀតជ្រែក។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ដោយសារការបំពេញការងាររបស់ខ្លួន។ នៅក្នុងអំឡុងពេលនៃការស្លាប់នេះ ជនរងគ្រោះចំនួន ១២នាក់ស្លាប់ដោយសារពាក់ព័ន្ធនឹងសកម្មភាពរាយការណ៍ព័ត៌មាន ដែលបង្កផលប៉ះពាល់ដោយផ្ទាល់ដល់បុគ្គលមានអំណាចនៅកម្ពុជា។ មកដល់បច្ចុប្បន្ននេះ មិនមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាព ឯករាជ្យភាព និងតម្លាភាព ត្រូវបានធ្វើឡើង ដើម្បីនាំជនល្មើសដែលបានប្រព្រឹត្តិបទឧក្រិដ្ឋមកផ្តន្ទាទោស បណ្តាលឱ្យករណីទាំងអស់នេះមិនត្រូវបានដោះស្រាយ ហើយជនរងគ្រោះមិនទាន់ទទួលបាននូវយុត្តិធម៌ ខណៈដែលជនល្មើសនៅតែបន្តរួចផុតពីការដាក់ទោសទណ្ឌដោយសារវប្បធម៌និទណ្ឌភាព។

ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានឆ្នាំ២០២៣ ម.ស.ម.ក នឹងរៀបចំយុទ្ធនាការចាប់ពីថ្ងៃទី២៨ ខែតុលា ដល់ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣។ តាមរយៈសកម្មភាពនៃយុទ្ធនាការនេះ ម.ស.ម.ក មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ និងអំពើនិទណ្ឌភាពដែលកំពុងបន្តញាំញីក្នុងប្រទេសកម្ពុជា រួមទាំងអំពើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានផងដែរ។ តាមរយៈយុទ្ធនាការនេះ ម.ស.ម.ក សង្ឃឹមថានឹង

ជំរុញឱ្យមានការផ្តន្ទាទោសលើជនល្មើសនៃឧក្រិដ្ឋកម្មទាំងនោះ និងអំពាវនាវឱ្យបញ្ចប់នូវអំពើនិទណ្ឌភាពលើករណីរបស់ពួកគេ។

សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- ថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយនូវប័ណ្ណព័ត៌មានស្តីពីទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន និងតួនាទីអ្នកសារព័ត៌មាន។
- ថ្ងៃទី៣០ ខែតុលា រហូតដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ម.ស.ម.ក នឹងផ្សព្វផ្សាយឡើងវិញនូវវីដេអូប្រវត្តិជនរងគ្រោះពីអំពើនិទណ្ឌភាពចំនួន១៥រូប ដែលជាអ្នកសារព័ត៌មាននិងអ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ។
- ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ ម.ស.ម.ក នឹងផ្សាយឡើងវិញនូវវីដេអូតុក្កតារឿង «**អ្នកបន្តវេន**» ដែលរៀបរាប់កិច្ចខិតខំប្រឹងប្រែងពីកូនប្រុសរបស់អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្លាប់ ក្នុងការស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្លួន និងចាក់ផ្សាយនូវកម្មវិធីវិទ្យុក្រោមប្រធានបទ«ទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន»។
- ថ្ងៃទី០២ខែវិច្ឆិកា ឆ្នាំ២០២៣ ម.ស.ម.ក និងចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមស្តីពី ទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន។
- នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយនូវប័ណ្ណព័ត៌មានស្តីពីការឃាយឃីលើអ្នកសារព័ត៌មានពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។
- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានពីចន្លោះខែកញ្ញា ឆ្នាំ២០២២ ដល់ខែសីហាឆ្នាំ២០២៣។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា លោក ហួន ផន តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ឬ អ្នកសម្របសម្រួលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា នៃ ម.ស.ម.ក លោក រស់ សារ៉ាត់ តាមរយៈអ៊ីម៉ែល rossarath@cchrcambodia.org ឬ ០១៧ ៨៨៦ ៦៩៥៕

<u>**ចប់**</u>

## បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសបែន (Brisbane) នៃប្រទេសអូស្ត្រាលី។